ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្ដីជូនដំណឹង

យោងតាមការជូនដំណឹង ចុះថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងការងារថៃ គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹង ដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងធ្វើការនៅក្នុងប្រទេសថៃឱ្យបានជ្រាបថា៖

ទី១. ក្នុងកំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនាពេលខាងមុខនេះ ភាគីកម្ពុជា និងថៃនឹងសហការគ្នា ដើម្បីសម្រួលដល់ពលករ ដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងពលករ ដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុក អាចធ្វើដំណើរចេញ-ចូលប្រទេសថៃ-កម្ពុជាបានចាប់ពីថ្ងៃទី០៥ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

ទី២. ចំពោះបងប្អូនពលករ កាន់ប័ណ្ណមិនមែនសញ្ជាតិថៃ(ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រលប់មកកម្ពុជាវិញក្នុងអំឡុងពេលនេះ ត្រូវទៅស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃក្នុងខេត្ត ដែលខ្លួនធ្វើការ។ ដោយឡែកចំពោះបងប្អូនពលករ ដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ(TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញ-ចូល (Re-Entry Visa) នៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬនៅច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃសេវាឡើយ។

ទី៣. ពលករទាំងអស់ត្រូវឆ្លងកាត់តាមច្រកព្រំដែនអន្តរជាតិ ហើយប្រសិនជាត្រលប់មកកម្ពុជាតាមច្រកណា ត្រូវត្រឡប់ទៅថៃវិញតាមច្រកនោះ។

ទី៤. ពលករកម្ពុជាកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) មិនតម្រូវឱ្យសុំលិខិតធ្វើដំណើរបណ្ដោះអាសន្ន (Laissez Passer) ដើម្បីធ្វើដំណើរត្រលប់មកកម្ពុជាវិញឡើយ ក្នុងអំឡុងពេលភាគីថៃ និងកម្ពុជាបានឯកភាពគ្នានេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន ពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៨